# អំពីកម្មវិធីចាក់ថ្នាំបង្ការថ្នាក់ជាតិ (NIP)

## កម្មវិធីចាក់ថ្នាំបង្ការថ្នាក់ជាតិ (NIP) ផ្តល់ជូនវ៉ាក់សាំងដោយឥតគិតថ្លៃដើម្បីការពារមនុស្សដែលមានសិទ្ធិទទួល ដើម្បីប្រឆាំងនឹងជំងឺជាច្រើនប្រភេទ។

NIP ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1997 ដោយរដ្ឋាភិបាលអូស្ត្រាលីក្នុងកិច្ចសហការជាមួយរដ្ឋាភិបាលរដ្ឋ និងដែនដី ដើម្បីបង្កើនអត្រានៃការចាក់ថ្នាំបង្ការថ្នាក់ជាតិ និងកាត់បន្ថយជំងឺនានាដែលអាចបង្ការបានដោយវ៉ាក់សាំង។

NIP ផ្តល់ជូនវ៉ាក់សាំងសំខាន់ៗដោយឥតគិតថ្លៃដល់មនុស្សដែលមានសិទ្ធិទទួលដូចជាទារក និងកុមារ ក្មេងជំទង់ ស្ត្រីមានផ្ទៃពោះ មនុស្សពេញវ័យ និងមនុស្សចាស់ ប្រជាជាតិដើមដំបូង និងអ្នកដែលមានស្ថានភាពសុខភាពមិនល្អដែលបណ្តាលឱ្យពួកគាត់ស្ថិតក្នុងហានិភ័យខ្ពស់នៃការអាចមានជំងឺធ្ងន់ធ្ងរ។

ដើម្បីស្វែងយល់ថាតើវ៉ាក់សាំងណាដែលអ្នក ឬក្រុមគ្រួសាររបស់អ្នកមានសិទ្ធិទទួលដោយឥតគិតថ្លៃ និងនៅពេលណា អ្នកអាចពិនិត្យមើលកាលវិភាគ NIP នៅតាមគេហទំព័រ www.health.gov.au/nipschedule ឬនិយាយជាមួយអ្នកជំនាញសុខភាពរបស់អ្នក។



## កាលវិភាគ NIP

កាលវិភាគ NIP គឺជាឈុតនៃការចាក់ថ្នាំបង្ការតាមវគ្គដែលបានផ្តល់ឱ្យនៅពេលវេលាជាក់លាក់ពេញមួយជីវិតរបស់អ្នក ចាប់ពីកំណើត រហូតដល់ពេញវ័យ។ ការចាក់វ៉ាក់សាំងតាមពេលវេលានៃកាលវិភាគ ផ្តល់នូវការការពារដ៏ល្អបំផុត។

ដើម្បីមានសិទ្ធិទទួលបានវ៉ាក់សាំង NIP ដោយឥតគិតថ្លៃ អ្នកត្រូវតែមាន ឬមានសិទ្ធិទទួលបានកាត Medicare។

កម្មវិធីនេះក៏ផ្តល់ជូនការចាក់វ៉ាក់សាំងដែលបានខកខាន ដោយផ្តល់ជូនឥតគិតថ្លៃផងដែរ ប្រសិនបើមិនបានចាក់ក្នុងវ័យកុមារភាពសម្រាប់៖

- មនុស្សដែលមានអាយុរហូតដល់ទៅ 20 ឆ្នាំ
- មនុស្សដែលមានអាយុក្រោម 26 ឆ្នាំដែលមិនបានចាក់វ៉ាក់សាំងបង្ការវីរុសដុះឫសលើអង្គជាតិមនុស្ស (HPV)
- ជនភៀសខ្លួន និងអ្នកចូលមកជ្រកកោនក្រោមកម្មវិធីមនុស្សធម៌គ្រប់វ័យ។

## កន្លែងដើម្បីទទួលបានវ៉ាក់សាំង NIP ដោយឥតគិតថ្លៃ

អ្នកអាចទទួលបានវ៉ាក់សាំង NIP ពីស្ថាប័នផ្តល់សេវាកម្មចាក់វ៉ាក់សាំងមួយចំនួនមានដូចជា៖

- មន្ទីរអ្នកជំនាញពិនិត្យព្យាបាលរោគទូទៅ
- គ្លីនិកចាក់ថ្នាំបង្ការសាលាសង្កាត់តាមមូលដ្ឋាន (មានជូននៅក្នុងរដ្ឋ និងដែនដីមួយចំនួន)
- មជ្ឈមណ្ឌលសុខភាពសហគមន៍
- សេវាកម្មវេជ្ជសាស្ត្រជនជាតិដើម Aboriginal
- ឱសថស្ថាន
- សាលារៀន (សម្រាប់ក្មេងជំទង់)។

វ៉ាក់សាំងទាំងអស់ដែលមានរាយឈ្មោះក្នុងកាលវិភាគ NIP គឺមិនគិតថ្លៃទេ។ ទោះជាយ៉ាងណាក៏ដោយ អ្នកជំនាញសុខភាពរបស់អ្នកអាចគិតថ្លៃពិគ្រោះយោបល់ ឬថ្លៃសេវាកម្ម។ សូមសាកសួរមើលថាតើមានថ្លៃសេវាកម្មណាមួយដែរឬទេ នៅពេលធ្វើការណាត់ជួបរបស់អ្នក។

Australian Government
Department of Health, Disability and Ageing

National Immunisation Program
A joint Australian, State and Territory Government Initiative

# អំពីកម្មវិធីចាក់ថ្នាំបង្ការថ្នាក់ជាតិ (NIP)

## ការធានាសុវត្ថិភាពវ៉ាក់សាំង

មុនពេលមានការអនុម័តឱ្យប្រើប្រាស់វ៉ាក់សាំងណាមួយនៅក្នុងប្រទេសអូស្ត្រាលី វ៉ាក់សាំងនោះត្រូវឆ្លងកាត់ការសាកល្បងផ្នែកវេជ្ជសាស្ត្រយ៉ាងទូលំទូលាយ និងការវាយតម្លៃយ៉ាងហ្មត់ចត់ដោយរដ្ឋបាលគ្រប់គ្រងលើទំនិញទាក់ទងនឹងការព្យាបាល (TGA)។

មានតែវ៉ាក់សាំងដែលបំពេញតាមស្តង់ដារសុវត្ថិភាព គុណភាព និងប្រសិទ្ធិភាពយ៉ាងហ្មត់ចត់ប៉ុណ្ណោះ ដែលទទួលបានការអនុម័ត។

នេះគឺជាផ្នែកនៃដំណើរការដ៏ទូលំទូលាយដែលត្រូវបានតម្រូវ មុនពេលវ៉ាក់សាំងអាចត្រូវបានចុះបញ្ជីក្នុង NIP។

នៅពេលវ៉ាក់សាំងណាមួយបានទទួលការអនុម័តឱ្យប្រើប្រាស់ សុវត្ថិភាពរបស់វាត្រូវបានបន្តត្រួតពិនិត្យយ៉ាងដិតដល់ ហើយមានការចាត់វិធានការដោយយកចិត្តទុកដាក់ និងការស៊ើបអង្កេតភ្លាមៗទៅលើកង្វល់ទាំងពួង។

## ការគ្រប់គ្រងវ៉ាក់សាំង

រដ្ឋាភិបាលអូស្ត្រាលីទទួលខុសត្រូវចំពោះ NIP និងការទិញវ៉ាក់សាំងនានាដែលគ្របដណ្តប់ដោយកម្មវិធីនេះ។ រដ្ឋាភិបាលរដ្ឋ និងដែនដីទទួលខុសត្រូវចំពោះការសម្របសម្រួល និងការត្រួតពិនិត្យការផ្តល់សេវាកម្មចាក់ថ្នាំបង្ការ និងការចែកចាយវ៉ាក់សាំង។ គណៈកម្មការ និងស្ថាប័នប្រឹក្សាជាច្រើនធ្វើការត្រួតពិនិត្យការរៀបចំបង្កើត និងការចែកចាយ NIP។

ប្រទេសអូស្ត្រាលីមានកម្មវិធីចាក់ថ្នាំបង្ការដែលបានផ្តល់មូលនិធិដោយរដ្ឋសម្រាប់សាធារណៈជន ដ៏ទូលំទូលាយបំផុតមួយនៅក្នុងពិភពលោក។

## ផលប៉ះពាល់នៃការចាក់វ៉ាក់សាំង

ជាលទ្ធផលនៃកម្មវិធីចាក់វ៉ាក់សាំងប្រកបដោយជោគជ័យ ជំងឺជាច្រើនត្រូវបានលុបបំបាត់ចោល ឬក៏កម្រមានណាស់នៅក្នុងប្រទេសអូស្ត្រាលី ដូចជារោគតេតាណូស ជំងឺគ្រុនផ្តាសាយ *Haemophilus influenzae* ប្រភេទ b (Hib) និងគ្រុនស្វិតដៃជើង (poliomyelitis)។[1]

ចំនួនប្រជាជនដ៏ច្រើនដែលបានចាក់វ៉ាក់សាំង ក៏បង្កើតភាពស៊ាំនៃហ្វូងមនុស្សផងដែរ ពីព្រោះនៅពេលដែលមនុស្សគ្រប់ចំនួនបានចាក់វ៉ាក់សាំង ឱកាសនៃការឆ្លងរាលដាលនៃជំងឺក៏មានកាន់តែតិចដែរ។ ភាពស៊ាំនៃហ្វូងមនុស្សត្រូវបានសម្រេចនៅពេលដែលអត្រាចាក់វ៉ាក់សាំងមានប្រហែលជា 95%។



**សម្រាប់ព័ត៌មានបន្ថែម និងធនធានព័ត៌មាន**អំពីការចាក់ថ្នាំបង្ការពីកុមារភាព រួមទាំងវីដេអូ សំណួរដែលគេសួរញឹកញាប់ និងខិត្តប័ណ្ណព័ត៌មានជាដើម សូមចូលទៅកាន់គេហទំព័រ health.gov.au/childhoodimmunisation

[1] https://immunisationhandbook.health.gov.au/contents/about-the-handbook

ព័ត៌មានទាំងអស់នៅក្នុងខិត្តប័ណ្ណព័ត៌មាននេះ គឺត្រឹមត្រូវគិតត្រឹមខែមិថុនា ឆ្នាំ 2026។

Australian Government
Department of Health, Disability and Ageing

National Immunisation Program
A joint Australian, State and Territory Government Initiative